**Declassified to Public**
**28 October 2021**



ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Mar-2015, 10:29
CMS/CFO: Sann Rada

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចលើសំណើនានាទាំងឡាយរបស់គាត់ដែលបានដាក់នាពេលកន្លងមក**

---

**ដាក់ដោយ:**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តាមរយៈនេះ ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសម្រេច ឬបើមិនដូច្នោះទេ បំពេញកិច្ចលើសំណើមួយចំនួនដែលគាត់បានដាក់ក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ ហើយដែលរហូតមកទល់ពេលបច្ចុប្បន្ននេះ ត្រូវបានសហចៅក្រមស៊ើបអង្កេតទុកចោលមិនចាត់ការ។ សំណើនេះគឺត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះសហចៅក្រមស៊ើបអង្កេតត្រូវដោះស្រាយបញ្ហាជាច្រើន ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់លោក មាស មុត។ កាលពីមុន សហចៅក្រមស៊ើបអង្កេត Harmon បានបដិសេធមិនធ្វើដូច្នេះ ដោយឈរលើមូលដ្ឋានថា គាត់មិនបានចាត់ទុកលោក មាស មុត ជាភាគីមួយនៃនីតិវិធីឡើយ។ ឥឡូវនេះសហចៅក្រមស៊ើបអង្កេត Harmon បានចាត់ទុកលោក មាស មុត ដោយចំៗ ជាភាគីនៃកិច្ចដំណើរការនីតិវិធី។[1] ហេតុដូច្នេះ ពេលវេលាគឺទុំជោរទៅហើយ។ បញ្ហាទាំងនេះ *ត្រូវតែ* ដោះស្រាយឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ មេធាវីការពារក្តីរាយតាមលំដាប់ដូចខាងក្រោមនូវសារណាទាំងនោះ ជាមួយនឹងការពន្យល់/ទឡ្ហីករណ៍ពាក់ព័ន្ធ ដែលតាមទស្សនៈរបស់មេធាវីការពារក្តី នៅតែទាមទារឱ្យមានការបំពេញកិច្ចដោយសហចៅក្រមស៊ើបអង្កេត[2]។

---

[1] មកទល់ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ នៅពេលដែលសហចៅក្រមស៊ើបអង្កេត Harmon បានកោះហៅលោក មាស មុត ឱ្យមកបង្ហាញខ្លួនលើកដំបូង ជាក់ស្តែងសហចៅក្រមស៊ើបអង្កេត Harmon បានសម្រេចចិត្តចោទប្រកាន់លោក មាស មុត រួចទៅហើយ ហេតុដូច្នេះ គាត់មិនគួរពន្យាពេលចាត់ការលើសារណាទាំងឡាយរបស់លោក មាស មុត ឡើយ។ *សូមមើល* ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។ អំណះអំណាងដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត Harmon ដែលថា *ប្រសិនបើ* គាត់ចោទប្រកាន់លោក មាស មុត បន្ទាប់ពីការបង្ហាញខ្លួនបឋមនោះ លោក មាស មុត នឹងត្រូវបានចាត់ទុកជាភាគី ហើយនឹងមានសិទ្ធិចូលពិនិត្យមើលសំណុំរឿងនោះ គឺជាការបោកប្រាស់យ៉ាងប្រាកដ ដោយពិចារណាថា គោលបំណងនៃកោះហៅលោក មាស មុត គឺដើម្បីចោទប្រកាន់គាត់។ *សូមមើល* ការជូនដំណឹងស្តីពីសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿងចូលរួមការស៊ើប អង្កេត និង សុំលុបចោលចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D82/5 កថាខណ្ឌ ១៦ ដែលចែង *នៅក្នុងចំណោមនោះ (inter alia)* ថា ប្រសិនបើលោក មាស មុត ត្រូវចោទនៅពេលដែលបញ្ចប់ការបង្ហាញខ្លួនលើកដំបូងនេះ គាត់នឹងអាច “អនុវត្តសិទ្ធិទាំងអស់ដែលជនត្រូវចោទមានសិទ្ធិទទួលបានតាមវិធានផ្ទៃក្នុង”។

[2] សារណាដទៃខ្លះទៀត មិនដែលត្រូវបានសម្រេច ឬបើមិនដូច្នោះទេ បំពេញកិច្ចដោយសហចៅក្រមស៊ើបអង្កេតឡើយ ប៉ុន្តែឥឡូវនេះបានក្លាយជាអាសារឥតការ ហើយដូច្នេះមិនត្រូវបានរាយឈ្មោះនៅខាងក្រោមនេះឡើយ។ សារណាទាំងនោះរួមមាន សំណើរបស់មាស មុត សុំការបញ្ជាក់បំភ្លឺពាក់ព័ន្ធថា តើមេធាវីការពារក្តីអាចធ្វើការស៊ើបអង្កេតនៅដំណាក់កាលបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធី ដែរឬយ៉ាងណា ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.12 សំណើរបស់ មាស មុត សុំការពន្យល់បំភ្លឺទាក់ទងនឹងស្ថានភាពនៃការស៊ើបអង្កេតរបស់តុលាការ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ D103/1.4 សំណើសុំព័ត៌មានទាក់ទងនឹងថា តើអ្នកជំនាញ ឬ អ្នកដទៃទៀត ត្រូវបានប្រឹក្សាដែរឬទេ នៅក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ A41.2។ សារណាដទៃទៀតហាក់ដូចជាត្រូវបានសម្រេចរួចហើយ បើទោះ

## I. បញ្ជីសារណាដែលតម្រូវឲ្យមានដំណោះស្រាយ

១. សំណើរបស់ មាស មុត សុំការបកស្រាយបំភ្លឺអំពីវិធី ដែលសហចៅក្រមស៊ើបអង្កេតចង់ប្រើដើម្បីគោរពសិទ្ធិរបស់ មាស មុត ទាក់ទងនឹងកិច្ចដំណើរការនីតិវិធី ក្នុងដំណាក់កាលមុនជំនុំជម្រះដែលនៅសល់ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D121។

- សារណានេះត្រូវបានដាក់ ដើម្បីធានាថាសិទ្ធិរបស់ លោក មាស មុត ត្រូវបានការពារ និង ដើម្បីធានាបាននូវតម្លាភាព និង សច្ចភាពផ្លូវច្បាប់ នៅក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលមុនជំនុំជម្រះនៅពេលខាងមុខ។ ទោះបីជាបញ្ហាមួយចំនួនដែលបានលើកឡើងនៅក្នុងសារណានេះ អាចទៅជាអាសារឥតការក្នុងពេលនេះ (ឧទាហរណ៍ ថាតើសហចៅក្រមស៊ើបអង្កេតចាត់ទុកថាអាចត្រូវបានអនុញ្ញាតឬទេ ឲ្យចោទប្រកាន់លោក មាស មុត *បន្ទាប់ពី* ការស៊ើបអង្កេតបានបញ្ចប់) ក៏សារណាលើកឡើងនូវបញ្ហាជាច្រើន ដែលនៅតែចាំបាច់ត្រូវដោះស្រាយ ដើម្បីធានាបាននូវតម្លាភាព និង ដើម្បីការពារសច្ចភាពផ្លូវច្បាប់។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

២. ពាក្យសុំរបស់ មាស មុត ស្នើឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និង ចាត់ការសំណើសុំមោឃភាពកិច្ចស៊ើបអង្កេតទាំងអស់ ដែលទាក់ទងនឹងការធ្វើទុក្ខបុកម្នេញខាងសាសនា ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D103/1.7។

- ពាក្យសុំមោឃភាពនេះត្រូវបានដាក់ ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ *មិន* បានលើកឡើងពីអង្គហេតុទាក់ទងនឹងការធ្វើទុក្ខបុកម្នេញខាងសាសនា ប៉ុន្តែបែរជាស្នើថាឲ្យស៊ើបអង្កេតលោក មាស មុត អំពីការធ្វើទុក្ខបុកម្នេញខាងសាសនា។
- ពាក្យសុំមោឃភាពហាក់ដូចជាហួសសម័យ ដោយសារតែពាក្យសុំស្នើឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើកិច្ចស៊ើបអង្កេតមួយចំនួន ដោយមិនបានចង្អុលបង្ហាញចំពោះកិច្ចស៊ើបអង្កេតជាក់លាក់ណាមួយ ដោយសារតែមេធាវីការពារក្តីមិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង នៅពេលដែលខ្លួនដាក់ពាក្យសុំមោឃភាពនេះ។ ទោះជាយ៉ាងនេះក្តី ក.ស.ច.ស. នៅតែត្រូវទទួល

---

បីជាដោយប្រយោលក៏ដោយ ហើយឥឡូវនេះសេចក្តីសម្រេចនេះនឹងត្រូវបានប្តឹងឧទ្ធរណ៍ ទៅអង្គបុរេជំនុំជម្រះ។ សារណាទាំងនោះរួមមាន ញត្តិរបស់ មាស មុត ប្រឆាំងការអនុវត្តបទឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា ៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. (បទឧក្រិដ្ឋកម្មជាតិ) ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.13 និង ញត្តិរបស់មាស មុត ប្រឆាំងការអនុវត្តការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយសារតែហួសអាជ្ញាយុកាល ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ D103/1.3។

ពិនិត្យ និង ចាត់ការលើពាក្យសុំមោឃភាពនេះ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេត បានបញ្ជូនពាក្យសុំមោឃភាពនេះទៅអង្គបុរេជំនុំជម្រះ មេធាវីការពារក្តីនឹងដាក់ទឡ្ហីករណ៍បន្ថែមទៀតជូនអង្គបុរេជំនុំជម្រះ ដើម្បីធ្វើបច្ចុប្បន្នភាពពាក្យសុំនេះ។

៣. ពាក្យសុំរបស់មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និង ចាត់ការសំណើសុំមោឃភាពកិច្ចស៊ើបអង្កេតទាំងអស់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួនពីរដែលរងការចោទប្រកាន់ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D103/1.6។

- ពាក្យសុំនេះត្រូវបានដាក់ពីព្រោះ "ចំការចូរេន នៅភូមិរាម ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និង ការដ្ឋានបិតត្រាំង នៅឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មិនមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេត Harmon បែរជាបានចង្អុលបង្ហាញនៅក្នុងសេចក្តីប្រកាសព័ត៌មានកាលពីខែ កុម្ភៈ ឆ្នាំ ២០១៣ ថា ទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនេះ ស្ថិតនៅក្នុងការស៊ើបអង្កេតក្នុងរឿងក្តី ០០៣។
- មេធាវីការពារក្តីបានដាក់ពាក្យសុំមោឃភាពនេះ ទាំងដែលខ្លួនមិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង។ បន្ទាប់ពីទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង មេធាវីការពារក្តីបានដឹងថា វាជាការត្រឹមត្រូវយ៉ាងប្រាកដ ដែលថាសហចៅក្រមស៊ើបអង្កេត Harmon កំពុងតែធ្វើការស៊ើបអង្កេតលើទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងពីរនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានចេញដីកាបញ្ជូនសំណុំរឿងមួលទៅពិនិត្យទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងពីរនេះ[3] ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតប ដោយអះអាងថា ទីតាំងឧក្រិដ្ឋកម្មអាចត្រូវបានស៊ើបអង្កេត ដោយមិនចាំបាច់មានការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ *នៅក្នុងចំណោមនោះ* ព្រោះថាទីតាំងទាំងនោះគឺពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតក្រោមការស៊ើបអង្កេត[4]។
- នៅពេលបន្ទាប់មក ទីតាំងឧក្រិដ្ឋកម្មទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ[5] ប៉ុន្តែស្ថានភាពនៃ

---

[3] ដីកាបញ្ជូនសំណុំរឿងមួលទៅពិនិត្យ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D47។

[4] ចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងដីកាបញ្ជូនសំណុំរឿងមួលទៅពិនិត្យ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ D47/1 កថាខណ្ឌ ៦ ដល់ ៧។

[5] ដីកាបញ្ជូនសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D120។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ គឺមិនច្បាស់លាស់ឡើយ៖ កថាខណ្ឌ ២៨ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ថ្លែងថាឯកសារនេះគឺ "ត្រូវបានដាក់អនុលោមតាម វិធាន ៧១(៣) នៃ វិធានផ្ទៃក្នុង"។ ពាក្យពេចន៍ទាំងនេះហាក់ដូចជាចង្អុលបង្ហាញថា រយៈពេល ដោះស្រាយការខ្វែងយោបល់គ្នាចំនួន ៣០ ថ្ងៃ ដូចមានចែងក្នុងវិធាន ៧១(៣) អាចមិនទាន់ កន្លងហួសនៅមុនពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ អង្គបុរេជំនុំជម្រះ អាចបានទទួលយកការខ្វែងយោបល់គ្នា ក្នុងអំឡុងពេលនេះ ដែលក្នុងករណីនេះដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមិនអាចត្រូវបានអនុវត្តឡើយ រហូតដល់ពេលដែលអង្គបុរេជំនុំ ជម្រះដោះស្រាយការខ្វែងយោបល់គ្នា។

- ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើពាក្យសុំមោឃភាពនេះ។ នៅពេលដែល សហចៅក្រមស៊ើបអង្កេតបានបញ្ជូនពាក្យសុំមោឃភាពទៅអង្គបុរេជំនុំជម្រះ មេធាវីការពារក្ដី នឹងដាក់ទឡ្ហីករណ៍បន្ថែមទៀត ជូនទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើបច្ចុប្បន្នភាពពាក្យសុំនេះ។

៤. សំណើរបស់មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេត ពន្យល់អំពីការយល់ឃើញរបស់ខ្លួនថា នឹង មានអ្វីកើតឡើង នៅក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត និង ចៅក្រមនៃអង្គបុរេជំនុំជម្រះ ខ្វែងយោបល់គ្នាទៅលើបញ្ហាដែលថា តើត្រូវបិទកិច្ចស៊ើបសួរ ឬ តើត្រូវចាប់ខ្លួន ត្រូវចោទប្រកាន់ ឬ ត្រូវកោះហៅលោក មាស មុត ឬយ៉ាងណា ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D103/1.5។

- សំណើនេះត្រូវបានដាក់ ដើម្បីសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការពន្យល់អំពីការយល់ឃើញ របស់ខ្លួន ថានឹងមានអ្វីកើតឡើង នៅក្នុងករណីសហចៅក្រមស៊ើបអង្កេត និង ចៅក្រមនៃអង្គ បុរេជំនុំជម្រះ ខ្វែងយោបល់គ្នាទៅលើបញ្ហាដែលថា តើត្រូវបិទកិច្ចស៊ើបសួរ ឬ តើត្រូវចាប់ខ្លួន ត្រូវចោទប្រកាន់ ឬ ត្រូវកោះហៅលោក មាស មុត ឬយ៉ាងណា។ សំណើនេះ ការពារសិទ្ធិ របស់លោក មាស មុត ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និង តម្លាភាព។
- នៅខណៈដែលឥឡូវនេះ មេធាវីការពារក្ដីបានដឹងអំពីជំហររបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលថាសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក៏អាចចាប់ខ្លួន និង ចោទប្រកាន់ជន សង្ស័យបានដែរនោះ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង មិនបានផ្ដល់ការយល់ឃើញ របស់ខ្លួន ចំពោះបញ្ហានេះឡើយ។ បន្ថែមលើនេះ គោលជំហររបស់សហចៅក្រមស៊ើបអង្កេត អំពីផលវិបាកនៃការខ្វែងយោបល់គ្នាទាក់ទងនឹងថា តើត្រូវបញ្ជូនរឿងក្ដីទៅជំនុំជម្រះឬយ៉ាង ណានោះ នៅតែមិនច្បាស់លាស់។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើ

សំណើនេះ។

៥. ញត្តិរបស់មាស មុត ប្រឆាំងការអនុវត្តសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.15។

- ញត្តិនេះត្រូវបានដាក់ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចោទប្រកាន់ថា លោក មាស មុត ត្រូវទទួលខុសត្រូវផងដែរ ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III ដែលជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលមិនត្រូវបានទទួលស្គាល់នៅ អ.វ.ត.ក.។
- ក្នុងពេលថ្មីៗនេះ សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខ ក្នុងរឿងក្តី ០០២/០១ ដោយចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារមិនបានពិចារណាលើការអនុវត្ត សហឧក្រិដ្ឋកម្មរួម ទម្រង់ទី III។ មេធាវីការពារក្តីក្នុងរឿងក្តី ០០៣ បានដាក់សំណើសុំធ្វើ អន្តរាគមន៍ ឬ សុំដាក់សារណា *របស់អ្នកមិនមែនជាភាគីនៃរឿងក្តី (amicus curiae)* ទាក់ទងនឹងបញ្ហានេះនៅក្នុងរឿងក្តី ០០២/០១។ សារណានេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ។ មេធាវីការពារក្តីស្នើថា ទឡ្ហីករណ៍ដែលមាននៅទីនេះ បំពេញបន្ថែមទៅលើទឡ្ហីករណ៍ ដែលធ្វើឡើងនៅក្នុងញត្តិរបស់មាស មុត ប្រឆាំងការអនុវត្តសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

៦. សំណើរបស់មាស មុត សុំឲ្យ ក.ស.ច.ស. ធ្វើការស្តាប់ចម្លើយសាក្សីសាជាថ្មី ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.14។

- សារណានេះត្រូវបានដាក់ ពីព្រោះលោក មាស មុត មានសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ក្នុងការពិនិត្យលើភស្តុតាងប្រឆាំងខ្លួនគាត់ ដែលជាសិទ្ធិដែលគាត់មិនអាចអនុវត្តបាន ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅក្នុងសំណុំរឿង មិនបានឆ្លុះបញ្ចាំងពីចម្លើយដែលសាក្សីបានផ្តល់ដោយពិតប្រាកដ ជាមួយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស.។ ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់លោក មាស មុត ក.ស.ច.ស. គួរតែពិនិត្យមើលលើកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងអស់ ដែលមាននៅក្នុងសំណុំរឿង ហើយសម្រេចថា តើសាក្សីណាម្នាក់ចាំបាច់ត្រូវធ្វើការស្តាប់ចម្លើយសាជាថ្មី ឬយ៉ាងណា ហើយចាំបាច់ត្រូវស្តាប់ឡើងវិញ ក្នុងកម្រិតណាដែរ។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

៧. សំណើរបស់មាស មុត សុំឱ្យ ក.ស.ច.ស. ដាក់ប្រតិចារឹកទាំងស្រុងនៃការស្តាប់ចម្លើយសាក្សីទាំងអស់ ទៅក្នុងសំណុំរឿង ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.8។

- សារណានេះត្រូវបានដាក់ ពីព្រោះលោក មាស មុត មានសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ក្នុងការពិនិត្យលើភស្តុតាងប្រឆាំងខ្លួនគាត់។ គាត់មិនអាចអនុវត្តសិទ្ធិនេះបានទេ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅក្នុងសំណុំរឿង មិនបានឆ្លុះបញ្ចាំងពីចម្លើយដែលសាក្សីបានផ្តល់ដោយពិតប្រាកដ ជាមួយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស.។ ការដាក់បញ្ចូលខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយសាក្សីទៅក្នុងសំណុំរឿង *ជំនួស (in lieu)* ឱ្យប្រតិចារឹក គឺមិនគ្រប់គ្រាន់នោះឡើយ ក្នុងការការពារសិទ្ធិរបស់លោក មាស មុត ក្នុងការត្រួតពិនិត្យមើលទៅលើភស្តុតាងប្រឆាំងគាត់។
- យោងតាមអនុស្សរណៈចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ដែលមាននៅក្នុងសំណុំរឿង[6] អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. មិនតម្រូវឱ្យថតសំឡេងការស្តាប់ចម្លើយសាក្សីឡើយ ហើយហាក់ដូចជាថា មានខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយសាក្សីមួយចំនួនតូចនៅក្នុងសំណុំរឿង។ ទោះជាយ៉ាងនេះក្តី ការថតសំឡេងដែល *មាន* គួរតែត្រូវបានធ្វើជាប្រតិចារឹក ហើយប្រតិចារឹកទាំងនេះគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

៨. សំណើរបស់ មាស មុត សុំឱ្យ ក.ស.ច.ស. បង្គាប់ឱ្យ ក.ស.ព. ផ្តល់ឱ្យមេធាវីការពារក្តីនូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួន ទាក់ទងនឹង "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.11។

- សំណើនេះត្រូវបានដាក់ ដោយសារតែមេធាវីការពារក្តីក្នុងពេលអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្នខ្ពស់នោះ អាចចាំបាច់ត្រូវដាក់សារណា ដើម្បីតតាំងនឹងការរំលោភបំពានឆន្ទានុសិទ្ធណាមួយ ដោយ ក.ស.ព. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើការចោទប្រកាន់លោក មាស មុត ដូចដែលបានអនុញ្ញាតដោយយុត្តិសាស្ត្ររបស់ អ.វ.ត.ក.។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

---

[6] សេចក្តីណែនាំស្តីពីការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ D61។

៩. សំណើរបស់ មាស មុត សុំឲ្យ ក.ស.ច.ស. ផ្តល់ឲ្យមេធាវីការពារក្តីនូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួន ទាក់ទងនឹង "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង បុគ្គលដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.10។

- សំណើនេះត្រូវបានដាក់ ដោយសារតែមេធាវីការពារក្តីក្នុងពេលអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយប្រុងប្រយ័ត្នខ្ពស់នោះ អាចចាំបាច់ត្រូវដាក់សារណា ដើម្បីតតាំងនឹងការរំលោភបំពានឆន្ទានុសិទ្ធណាមួយ ដោយ ក.ស.ច.ស. ក្នុងសេចក្តីសម្រេចរបស់ខ្លួនលើការស៊ើបអង្កេតលោក មាស មុត ដូចដែលបានអនុញ្ញាតដោយយុត្តិសាស្ត្ររបស់ អ.វ.ត.ក.។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

១០. សំណើរបស់មាស មុត សុំការបញ្ជាក់បំភ្លឺថា តើ ក.ស.ច.ស. ពិចារណាថាខ្លួនត្រូវបានចងកាតព្វកិច្ចនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ឬយ៉ាងណា ដែលថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.7។

- សំណើនេះត្រូវបានដាក់ ដើម្បីជាផលប្រយោជន៍នៃសច្ចភាពផ្លូវច្បាប់ ដោយសារតែបញ្ហាគតិយុត្តិនេះ នៅតែមិនទាន់ត្រូវបានដោះស្រាយ នៅ អ.វ.ត.ក.៖ ក្នុងរឿងក្តី ០០២ អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូង មានការខ្វែងយោបល់គ្នា។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ គឺជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ចំណែកអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនចាំបាច់ត្រូវមានទំនាក់ទំនងនេះទេ។
- ចាប់តាំងពីពេលដាក់សំណើនេះមក អង្គបុរេជំនុំជម្រះបានបញ្ជាក់ជាឯកច្ឆន្ទថា៖

  ពាក់ព័ន្ធនឹងលក្ខណៈជាកាតព្វកិច្ចនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ទៅលើសហចៅក្រមស៊ើបអង្កេត យើងយល់ថា គោលការណ៍សច្ចភាពផ្លូវច្បាប់ និង សមភាពចំពោះមុខច្បាប់ ដែលមានចែងក្នុងវិធានផ្ទៃក្នុង និង ជាផ្នែកមួយនៃបទដ្ឋានអន្តរជាតិ ជាគោលការណ៍តម្រូវឲ្យសហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តតាម *ភាពសមហេតុផល (ratio decidendi)* នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលជាគោលការណ៍ច្បាប់ ដែលសេចក្តីសម្រេចណាមួយត្រូវយកមកសំអាង និង ដែលត្រូវអនុវត្តនៅក្នុងករណីស្រដៀងគ្នា ឬ មានខ្លឹមសារស្រដៀងគ្នា។ លក្ខណៈជាកាតព្វកិច្ចនេះ ក៏ត្រូវបានគាំទ្រផងដែរ ដោយឋានានុក្រមរបស់អង្គបុរេជំនុំជម្រះ ទៅលើសហចៅក្រមស៊ើបអង្កេត ក្រោមប្រព័ន្ធច្បាប់

អ.វ.ត.ក. និង ក៏ជាប្រយោជន៍នៃសេដ្ឋកិច្ចតុលាការ និង ប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយសារថាសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ដែលជាគោលការណ៍ត្រូវអនុវត្តតាមសេចក្ដីសម្រេចពីមុនរបស់ខ្លួន អនុលោមទៅតាមបទដ្ឋានដែលមានរៀបរាប់ខាងលើ និង អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹងច្រានចោលសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលងាកចេញពីយុត្តិសាស្ត្រពីមុនរបស់ខ្លួន[7]។

- ហេតុដូច្នេះ ក.ស.ច.ស. គ្រាន់តែបញ្ជាក់ថាខ្លួនមានចេតនាអនុវត្តស្របតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ចំពោះបញ្ហានេះប៉ុណ្ណោះ។ មេធាវីការពារក្ដីកត់សម្គាល់ថា ការជូនដំណឹងពីការចោទប្រកាន់ ប្រឆាំងមាស មុត[8] នៅក្នុងការពិភាក្សាពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនបាននិយាយពីបញ្ហាលក្ខខណ្ឌតម្រូវទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធឡើយ។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

១១. សំណើរបស់មាស មុត សុំឱ្យផ្ដល់លិខិតឆ្លើយឆ្លងរបស់ប្រធានក្រុមអ្នកច្បាប់របស់ ក.ស.ច.ស. ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ និង ឯកសារពាក់ព័ន្ធទាំងអស់ ព្រមទាំងសុំឱ្យដាក់ឯកសារទាំងនេះទៅក្នុងសំណុំរឿង ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.6។

- សារណានេះត្រូវបានដាក់ ដោយសារតែសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការស៊ើបអង្កេតដោយយុត្តិធម៌ ឯករាជ្យ និង឵ ឥតលម្អៀង អាចត្រូវបាន ហើយបន្តត្រូវបានធ្វើឱ្យខូចខាត ដោយសារការណ៍ដែលក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស. បានស្នើសុំឱ្យអង្គការសហប្រជាជាតិ ធ្វើអន្តរាគមន៍លើសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការស៊ើបអង្កេតតាមផ្លូវតុលាការ។ សកម្មភាពរបស់ក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស. ធ្វើឱ្យមានចំណោទអំពីភាពសុចរិត ភាពឯករាជ្យ និង ភាពមិនលម្អៀងរបស់ក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស. របស់សហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់ និង កិច្ចស៊ើបអង្កេតទាំងមូល។ លោក មាស មុត មានសិទ្ធិទទួលបានការជូនដំណឹង ប្រសិនបើមានព័ត៌មានដែលគួរឱ្យជឿជាក់បានណាមួយ ដែលបង្ហាញពីកង្វះភាពឯករាជ្យ ឬ ភាពមិនលម្អៀងនៅក្នុង

---

[7] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ មាស មុត ចំនួនដប់បួនច្បាប់ ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2 កថាខណ្ឌ ២៧។

[8] ការជូនដំណឹងពីបទចោទប្រឆាំង មាស មុត ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D128.1។

ក.ស.ច.ស.។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

១២. សេចក្តីជូនដំណឹងរបស់មាស មុត ស្តីពីការបដិសេធមិនឲ្យ David Boyle ជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៣ បន្តទៅទៀត និង សំណើសុំឲ្យបង្ហាញលទ្ធផលការងារកន្លងមករបស់ David Boyle ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.5។

- សេចក្តីជូនដំណឹងនេះត្រូវបានដាក់ ដោយសារតែលោក មាស មុត មានសិទ្ធិទទួលបានការស៊ើបអង្កេតដោយយុត្តិធម៌ និង មិនលម្អៀង។ លោក Boyle មានភាពលម្អៀង ហើយការចូលរួមណាមួយរបស់គាត់នៅក្នុងរឿងក្តី ០០៣ ទោះជានៅក្នុងឋានៈអ្វីក៏ដោយ នឹងធ្វើឲ្យខូចដល់កិច្ចស៊ើបអង្កេតនេះ។ ក្នុងការអនុវត្តកាតព្វកិច្ចដោយការប្រុងប្រយ័ត្នខ្ពស់ មេធាវីការពារក្តី *ត្រូវ* តែពិនិត្យមើលឡើងវិញនូវលទ្ធផលការងាររបស់លោក Boyle ដើម្បីសម្រេចថាតើចាំបាច់ ឬ មិនចាំបាច់ ក្នុងការដាក់ពាក្យសុំមោឃភាពកិច្ចស៊ើបអង្កេត អនុលោមតាមវិធាន ៧៦។
- ខណៈដែលឥឡូវនេះ មេធាវីការពារក្តីមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ក៏នៅតែមិនច្បាស់លាស់ដែរ ថាតើលទ្ធផលការងាររបស់លោក Boyle មាននៅក្នុងសំណុំរឿងឬអត់ ហើយតើមេធាវីការពារក្តីអាចពិនិត្យបានឬអត់។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសេចក្តីជូនដំណឹង និង សំណើនេះ។

១៣. សេចក្តីជូនដំណឹងរបស់មាស មុត ស្តីពីការបដិសេធមិនឲ្យ Stephen Heder ជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៣ បន្តទៅទៀត និង សំណើសុំឲ្យបង្ហាញលទ្ធផលការងារកន្លងមករបស់ Stephen Heder ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.4។

- សេចក្តីជូនដំណឹងនេះត្រូវបានដាក់ ដោយសារតែលោក មាស មុត មានសិទ្ធិទទួលបានការស៊ើបអង្កេតដោយយុត្តិធម៌ និង មិនលម្អៀង។ លោក Heder មានភាពលម្អៀង ហើយការចូលរួមណាមួយរបស់គាត់នៅក្នុងរឿងក្តី ០០៣ ទោះជានៅក្នុងឋានៈអ្វីក៏ដោយ នឹងធ្វើឲ្យខូចដល់កិច្ចស៊ើបអង្កេតនេះ។ ក្នុងការអនុវត្តកាតព្វកិច្ចដោយការប្រុងប្រយ័ត្នខ្ពស់ មេធាវីការពារក្តី *ត្រូវ* តែពិនិត្យមើលលទ្ធផលការងាររបស់លោក Heder ដើម្បីសម្រេចថាតើចាំបាច់ ឬ មិនចាំបាច់ ក្នុងការដាក់ពាក្យសុំមោឃភាពកិច្ចស៊ើបអង្កេត អនុលោមតាមវិធាន ៧៦។
- ខណៈដែលឥឡូវនេះ មេធាវីការពារក្តីមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ក៏នៅតែមិនច្បាស់លាស់ដែរ ថាតើលទ្ធផលការងាររបស់លោក Heder មាននៅក្នុងសំណុំរឿងឬអត់ ហើយតើមេធាវីការពារក្តីអាចពិនិត្យបានឬអត់។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសេចក្តីជូនដំណឹង និង សំណើនេះ។

១៤. សំណើរបស់មាស មុត សុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ដែលពាក់ព័ន្ធក្នុងការអនុវត្តកិច្ចស៊ើបអង្កេតដែលមិនត្រឹមត្រូវក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.9។

- សំណើនេះត្រូវបានដាក់ ដោយសារតែអតីតអ្នកស៊ើបអង្កេត ឬ អ្នកស៊ើបអង្កេតបច្ចុប្បន្នមួយចំនួននៃ ក.ស.ច.ស. ត្រូវបានជឿជាក់ថា បានចូលរួមក្នុងការអនុវត្តការស៊ើបអង្កេតដែលមិនត្រឹមត្រូវ និង មិនប្រក្រតី ក្នុងរឿងក្តី ០០២។ មេធាវីការពារក្តីត្រូវតែពិនិត្យមើលឡើងវិញលើលទ្ធផលការងាររបស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ទាំងនេះនៅក្នុងរឿងក្តី ០០៣ ដើម្បីសម្រេចថាតើចាំបាច់ដែរឬទេ ក្នុងការដាក់ពាក្យសុំមោឃភាពកិច្ចស៊ើបអង្កេត អនុលោមតាមវិធាន ៧៦។
- ខណៈដែលឥឡូវនេះ មេធាវីការពារក្តីមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ក៏នៅតែមិនច្បាស់លាស់ដែរ ថាតើលទ្ធផលការងារទាំងអស់របស់អ្នកស៊ើបអង្កេតទាំងនេះ មាននៅក្នុងសំណុំរឿងឬអត់ ហើយតើមេធាវីការពារក្តីអាចពិនិត្យបានឬអត់។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

១៥. សំណើរបស់មាស មុត សុំព័ត៌មានទាក់ទងវិធីសាស្ត្រ និង មធ្យោបាយស៊ើបអង្កេតរបស់ ក.ស.ច.ស. ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ D87/2/1.3។

- សំណើនេះត្រូវបានដាក់ ដោយសារតែមិនអាចមើលឃើញច្បាស់លាស់ ថាតើកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការដែលមានភាពយុត្តិធម៌ មានការប្រុងប្រយ័ត្ន និង គ្រប់ជ្រុងជ្រោយ ត្រូវបានអនុវត្តដែរឬយ៉ាងណា និង ថាតើមានមធ្យោបាយស៊ើបអង្កេតរួមគ្នា (ឧទាហរណ៍ គំរូដែលមានភាពយុត្តិធម៌ ស៊ីសង្វាក់គ្នា និង មានតម្លាភាព) ដែលត្រូវបានគោរពតាមយ៉ាងហ្មត់ចត់ ដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស. ដែរឬយ៉ាងណា។
- ខណៈដែលឥឡូវនេះ មេធាវីការពារក្តីមានសិទ្ធិចូលពិនិត្យមើល *លទ្ធផល* នៃការស៊ើបអង្កេតតាមផ្លូវតុលាការក៏ដោយ ក៏វិធីសាស្ត្រ និង មធ្យោបាយស៊ើបអង្កេតនៅតែមិនច្បាស់លាស់។ ក.ស.ច.ស. នៅតែត្រូវទទួលពិនិត្យ និង ចាត់ការលើសំណើនេះ។

## II. ដំណោះស្រាយដែលស្នើសុំ

**អាស្រ័យ**ដូចបានបង្ហាញជូនក្នុងសំអាងហេតុខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតមេត្តា **សម្រេច** ឬបើមិនដូច្នោះ ធ្វើចំណាត់ការលើសារណាដែលបានរៀបរាប់ខាងលើ ដោយគ្មានការពន្យារពេល។

សូមលោកសហចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **១៧** ខែ **មីនា** ឆ្នាំ **២០១៥**
សហមេធាវីការពារក្តីលោក មាស មុត

_________________ _____________________

អាង ឧត្តម Michael G. KARNAVAS